# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ប្រចាំខែ កញ្ញា/តុលា ឆ្នាំ ២០១៤ /September/October, 2014**

**មាតិកា** **ទំព័រ**/Page


- អត្ថាធិប្បាយសង្ខេប/Briefing ២
- សូចនាករនាំមុខ/Leading Indicators ៦
- អតិផរណា និងទុនបំរុង/Inflation and Reserve ៧
- អត្រាប្តូរប្រាក់/Exchange Rates ៨
- រូបិយវត្ថុ និង ធនាគារ/Money and Banking ៩
- ថវិកា /BudgetExecution ១០
- វិនិយោគឯកជន/Private investment ១១
- ពាណិជ្ជកម្ម/Trades ១២


រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៤

**ប្រធាននាយកដ្ឋានស្ថិតិ**

# សង្ខេបនិន្នាការសេដ្ឋកិច្ចសង្គម

## សេដ្ឋកិច្ចក្នុងស្រុក

**វិស័យទេសចរណ៍**÷ នៅខែ កញ្ញា ឆ្នាំ ២០១៤ ចំនួនភ្ញៀវទេសចរណ៍មកដល់កម្ពុជាមានចំនួន ៣១១ ពាន់នាក់ ឬ បានថយចុះ ១០,៣ ភាគរយ បើធៀបនឹងខែមុន ។ តាមការសង្កេត ចំនួនភ្ញៀវទេសចរណ៍មាននិន្នាការធ្លាក់ចុះនៅចុងត្រីមាសទី៣នៃឆ្នាំ គឺជាការធ្លាក់ចុះតាមរដូវកាល ។ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៣ ចំនួនភ្ញៀវទេសចរណ៍សរុបបានកើនឡើង ៩,៧ ភាគរយ ក្នុងនោះ តាមច្រកអាកាសភ្នំពេញបានកើនឡើង ៥ ភាគរយ តាមច្រកអាកាសសៀមរាបបានកើនឡើង ២២ ភាគរយ និង ផ្លូវគោកនិងទឹកបានកើនឡើង ៥,៧ ភាគរយ ។ ក្នុងរយៈពេល៩ខែដើមឆ្នាំនេះ ចំនួនភ្ញៀវទេសចរណ៍សរុបបានកើនឡើង ៣,២ លាននាក់ ឬ បានកើនឡើងចំនួន ៤,៦ ភាគរយ ។

**វិស័យពាណិជ្ជកម្ម**÷ ***ការនាំចូល*** នៅខែ កញ្ញា ឆ្នាំ ២០១៤ នេះការនាំចូលសរុបគិតជាទឹកប្រាក់មានតម្លៃ ៩៧១,៤ លានដុល្លា គឺបានកើនឡើងប្រមាណ ១,៣ ភាគរយ បើធៀបទៅនឹងខែមុន ក្នុងនោះ ការនាំចូលប្រេងឥន្ធនៈធៀបនឹងខែមុនបានកើនឡើងប្រមាណ ២,៨ ភាគរយ ក្នុងខណៈដែលការនាំចូលបរិក្ខាសំណង់បានថយចុះ ៥,១ ភាគរយ វត្ថុធាតុដើមសម្រាប់ផលិតផលវាយនភ័ណ្ឌថយចុះ ២,៦ ភាគរយ និងការនាំចូលយានយន្តបានថយចុះ ៧,៤ ភាគរយ ។ បើប្រៀបធៀបទៅនឹងខែ កញ្ញា ឆ្នាំកន្លងទៅ ការនាំចូលសរុបបានកើនឡើង ៤៩,៥ ភាគរយ ដែលក្នុងនោះការនាំចូលបរិក្ខាសំណង់បានកើនឡើង ៦៨ ភាគរយ គ្រឿងយន្តបានកើឡើង ៣៤ ភាគរយ វាយនភណ្ឌកើនឡើង ៤ ភាគរយ និងប្រេងឥន្ធនៈបានកើនឡើង ២១ ភាគរយ ។ ក្នុងរយៈពេល៩ខែដើមឆ្នាំនេះ ការនាំចូលសរុបទឹកប្រាក់មានតម្លៃប្រមាណជាង ៧ ពាន់លានដុល្លារ ឬ បានកើនឡើងប្រមាណជា ១៦ ភាគរយ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ ។

***ការនាំចេញ*** នៅខែ កញ្ញា ឆ្នាំ ២០១៤ ការនាំចេញសរុបគិតជាទឹកប្រាក់មានតម្លៃ ៥៧៩,២ លានដុល្លារ មានការថយចុះ ២៩,៥ ភាគរយ ធៀបទៅនឹងខែមុន ក្នុងនោះផលិតផលកាត់ដេរមានការថយចុះ ៣២,៣ ភាគរយ និងកៅស៊ូបានថយចុះ ១២,០ ភាគរយ ដោយឡែកការនាំចេញអង្ករបានកើនឡើង ២,២ ភាគរយ ធៀបនឹងខែមុន ។ បើប្រៀបធៀបទៅនឹងខែ កញ្ញា ឆ្នាំកន្លងទៅ ការនាំចេញទំនិញសរុបបានថយ

ចុះ ២,៩ ភាគរយ ដែលក្នុងនោះការនាំចេញផលិតផលវាយនភ័ណ្ឌបានថយចុះ ៦,៨ ភាគរយ និង កៅស៊ូបានថយចុះ ២៥,៧ ភាគរយ ដោយឡែកការនាំចេញអង្ករបានកើនឡើង ៤,៨ ភាគរយ ។ ក្នុងរយៈពេល៩ខែដើមឆ្នាំនេះ ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិសរុបទឹកប្រាក់មានតំលៃប្រមាណជា ៦ ពាន់លានដុល្លារ ឬ បានកើនឡើង ១៥,២ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

***សន្ទស្សន៍ថ្លៃទំនិញ÷*** គិតមកដល់ខែ កញ្ញា ឆ្នាំ ២០១៤ សន្ទស្សថ្លៃទំនិញ មានការប្រែប្រួលតិចតួចគឺ អតិផរណាប្រចាំឆ្នាំ (Year on year) មានចំនួន ៣,៦ ភាគរយ ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (Year Average) មានចំនួន ៤,៤ ភាគរយ ។ តាមការប៉ាន់ស្មានដល់ដំណាច់ឆ្នាំ ២០១៤ អតិផរណាប្រចាំឆ្នាំអាចមានចំនួន ២,៨ ភាគរយ ឬ អតិផរណាមធ្យមប្រចាំឆ្នាំមានចំនួន ៤,១ ភាគរយ ។ ទោះជាទំហំអតិផរណារួមមានតម្លៃទាបក្រោម ៥ ភាគរយ ក៏ដោយ ក៏មានថ្លៃទំនិញខ្លះនៅក្នុងកន្ត្រក់ថ្លៃទំនិញនេះនៅមានការកើនឡើងខ្ពស់លើសពី ៥ ភាគរយ ដែរ ដូចជា÷ សាច់ជ្រូកបានកើនឡើង ១០,១ ភាគរយ ត្រីបានកើនឡើង ៤,៨ ភាគរយ និង ផ្លែឈើបានកើនឡើង ៩,៧ ភាគរយ ។ ការឡើងខ្ពស់ថ្លៃម្ហូបអាហារមួយចំនួន ដូចជា ថ្លៃត្រី សាច់ជ្រូក និងបន្លែផ្លែឈើ គឺកើតមានឡើងទៅតាមរដូវកាល ជាពិសេសរដូវបុណ្យទាន ក្នុងខណៈដែលកម្ពុជាបច្ចុប្បន្ន តម្រូវការប្រើប្រាស់ក្នុងស្រុកមានការកើនឡើង ជាមួយនឹងការផ្គត់ផ្គង់ដោយផលិតផលក្នុងស្រុក និងការនាំចូលពីខាងក្រៅមិនទាន់មានស្ថេរភាពល្អប្រសើរឆ្លើយតបទៅនឹងតម្រូវការប្រចាំថ្ងៃ នេះបើតាមការសង្កេត ។

**ការវិនិយោគ÷** គម្រោងវិនិយោគឯកជនដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) នៅខែតុលា ឆ្នាំ ២០១៤ មានការធ្លាក់ចុះ ទាំងទុនវិនិយោគ និងការបង្កើតការងារ បើធៀបនឹងខែមុន និង ក៏ដូចគ្នាដែរ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ កន្លងទៅ ។ ក្នុងរយៈពេល១០ខែដើមឆ្នាំនេះ ចំនួនគម្រោងបានកើនឡើង ៨,៨ ភាគរយ ដែលភាគច្រើនជាប្រភេទគម្រោងមានទំហំតូចជាងគម្រោងអនុម័តកាលពីឆ្នាំកន្លងទៅ ប៉ុន្តែចំនួនទុនវិនិយោគ និង ការបង្កើតការងារ នៅតែមានការធ្លាក់ចុះ ។

***សំណង់÷*** នៅខែ កញ្ញា ឆ្នាំ ២០១៤ ចំនួនគម្រោងបានស្នើសុំសាងសង់សរុបទូទាំងប្រទេសដែលបានអនុម័តរួច មានចំនួន ២២៧ គម្រោង គឺច្រើនជាងខែមុន ដែលមានចំនួន ១៧២ គម្រោង ។ ផ្ទៃក្រឡាសាងសង់បានធ្លាក់ចុះប្រមាណជា ៤៤ ភាគរយ និង ទឹកប្រាក់ក៏បានធ្លាក់ចុះប្រមាណជា ៤៦,៤ ភាគរយ ផងដែរ ។ បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៣ ចំនួនគម្រោងបានកើនឡើងចំនួន ៥៧,៦ ភាគរយ

ប៉ុន្តែ ចំនួនផ្ទៃក្រឡា និងទឹកប្រាក់បានថយចុះទៅវិញ ។ ក្នុងរយៈពេល៩ខែដើមឆ្នាំនេះ គម្រោងសរុបមានចំនួន ១,៨២១ គម្រោង ឬ បានកើនឡើង ៤៦,៦ ភាគរយ។

**ថវិកា÷** ***ចំណូល*** នៅខែ កញ្ញា ឆ្នាំ ២០១៤ នៅរដ្ឋបាលកណ្តាលចំណូលក្នុងស្រុកអនុវត្តបានចំនួន ៨៤៩,៣៥ ពាន់លានរៀល គឺបានកើនឡើង ៣២,៦ ភាគរយ ធៀបនឹងខែ កញ្ញា ឆ្នាំមុន ។ ចំណូលពីអគ្គនាយកដ្ឋានពន្ធដារបានកើនឡើង ១០ ភាគរយ និងអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ៤៤ ភាគរយ ។ ក្នុងរយៈពេល៩ខែដើមឆ្នាំ ២០១៤ ចំណូលក្នុងស្រុកសរុបអនុវត្តបានចំនួន ៧.៦៣៩,៧៤ ពាន់លានរៀល គឺខ្ពស់ជាង ១,៨ ភាគរយ នៃគោលដៅប្រមូលរយៈពេល៩ខែ[1] ដើមឆ្នាំ និងបានកើនឡើង ២៨,៥ ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

***ចំណាយ*** នៅខែ កញ្ញា ឆ្នាំ ២០១៤ ចំណាយសរុបអនុវត្តបានចំនួន ៦៧៩,៥៥ ពាន់លានរៀល គឺទាបជាង ៣៥,២ ភាគរយ បើធៀបនឹងខែ កញ្ញា កាលពីឆ្នាំមុន ។ ការធ្លាក់នេះ គឺដោយសារចំណាយចរន្តបានថយចុះ ១០,៨ ភាគរយ និង ចំណាយមូលធនបានថយចុះ ៧១,៤ ភាគរយ ។ ក្នុងរយៈពេល៩ខែដើមឆ្នាំ ២០១៤ ចំណាយសរុបអនុវត្តបានចំនួន ៦.៨៥៩,៨១ ពាន់លានរៀល គឺទាបជាង ២៣,៣ ភាគរយ នៃគោលដៅអនុវត្តថវិការយៈពេល៩ខែ ឬ បានថយចុះ ១៨,២ ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ ។ ការថយចុះនេះ គឺដោយសារការអនិវត្តចំណាយមូលធនបានថយចុះ ប្រមាណជា ៤៥ ភាគរយ ក្នុងនោះចំណាយមូលធនដែលមានប្រភពហិរញ្ញប្បទានពីបរទេសបានថយចុះប្រមាណ ៥៦,៦ ភាគរយ ។

តុល្យភាពថវិកាចរន្តនៅខែ កញ្ញា ឆ្នាំ ២០១៤ មានអតិរេកជាសាច់ប្រាក់ចំនួន ២៧១,៩២ ពាន់លានរៀល និង នៅរយៈពេល៩ខែដើមឆ្នាំនេះ អតិរេកចរន្តមានចំនួន ២.៤០៩,១៧ ពាន់លានរៀល ។

**រូបិយវត្ថុ÷** រយៈពេល៩ខែនេះ រូបិយវត្ថុទូទៅ (M2) មានកំណើនជាមធ្យម ២,៥ ភាគរយ ក្នុងមួយខែ និងសម្រាប់ខែ កញ្ញានេះ រូបិយវត្ថុទូទៅ(M2) មានកំណើនត្រឹមតែ២,០ ភាគរយ ។ ក្នុងនោះ រូបិយវត្ថុ (M1) កើនឡើង ០,៧ ភាគរយ ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ(រ)កើនឡើង ៨,៥ ភាគរយ និង ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសកើនឡើង ២,០ ភាគរយ ។ បើធៀបនឹងឆ្នាំមុន រូបិយវត្ថុទូទៅ (M2) មានកំណើនដល់ ៣៨,៩ ភាគរយ ក្នុងនោះ រូបិយវត្ថុ (M1) កើនឡើង ១៨,៣ ភាគរយ ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ(រ)កើនឡើង ៩,១ ភាគរយ និង ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសកើនឡើង ៤៤,១ ភាគរយ ។

[1] គោលដៅប្រមូលរយៈពេលប្រាំបួនខែ = (ច្បាប់ថវិកាប្រចាំឆ្នាំ/១២)* ៩ខែ

នៅខែ កញ្ញា ប្រាក់រៀលដែលចរាចរនៅលើទីផ្សារកើនឡើង ១,៨ ភាគរយ ធៀបទៅនឹងខែមុន ហើយអត្រាសាច់ប្រាក់រៀលធៀបរូបិយវត្ថុទូទៅ (M2) មានចំនួន ១៦,១ ភាគរយ ។ រយៈពេល៩ខែនេះ អត្រាសាច់ប្រាក់រៀលធៀបរូបិយវត្ថុទូទៅ (M2) មានចំនួនជាមធ្យម ១៧ ភាគរយ ។ ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើប្រាស់សាច់ប្រាក់ក៏មានកំណើនខ្ពស់ដែរ ហើយក្នុងនោះសាច់ប្រាក់ប្រើប្រាស់ជារូបិយប័ណ្ណបរទេសមានអត្រាកើនឡើងគឺពី ៧៨,៧ ភាគរយ នៅឆ្នាំ ២០០៩ ទៅ ៨២,២ ភាគរយ នៅឆ្នាំ ២០១៣ និងមានអត្រា ៨៣ ភាគរយ នៅខែ សីហា ឆ្នាំ ២០១៤ ។ កត្តានេះបញ្ជាក់ឱ្យឃើញថា ដុល្លារូបនីយកម្មនៅកម្ពុជានៅតែមានកំរិតខ្ពស់ និងបន្តកើនឡើង ។ (ទំហំដុល្លារូបនីយកម្មអាចគណនាតាម ៣ វិធីសាស្ត្រគឺ÷ ទី១ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសធៀបនឹងរូបិយវត្ថុទូទៅ (M2) ទី២ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសធៀបនឹងប្រាក់បញ្ញើសរុប និងទី៣ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបូកនឹងប្រាក់ដុល្លារចរាចរ (ប៉ាន់ស្មាន)រួចធៀបនឹងរូបិយវត្ថុទូទៅ (M2)) ។

## ថ្លៃទំនិញលើទីផ្សារអន្តរជាតិ

**ថ្លៃប្រេងឆៅ÷** នៅខែ តុលា ឆ្នាំ ២០១៤ តម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (Oil Brent) សម្រាប់កិច្ចសន្យាលក់មួយខែខាងមុខបានថយចុះ ១០,៣ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៩៧,៣ ដុល្លារ/ធុង មក ៨៧,៣ ដុល្លារ/ធុង ។ ការធ្លាក់ចុះតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិនេះ គឺដោយសារការផ្គត់ផ្គង់ប្រេងពី ប្រទេសមិនមែនសមាជិក OPEC មានការកើនឡើងយ៉ាងកំហុកលើសតម្រូវការលើទីផ្សារពិភពលោក ។

**ថ្លៃអង្ករ÷** នៅខែ តុលា ឆ្នាំ ២០១៤ នៅទីក្រុងបាងកកអង្ករនាំចេញ (ខ្ទេច ២៥ ភាគរយ) មានតម្លៃ ៤១០ ដុល្លារ/តោន គឺ បានថយចុះ ០,២ ភាគរយ ធៀបទៅនឹងខែមុន ដែលមានតម្លៃ ៤១១ ដុល្លារ/តោន ។ ចំណែកឯនៅប្រទេសវៀតណាមវិញ នៅខែ តុលា ឆ្នាំ ២០១៤ អង្ករនាំចេញ (ខ្ទេច ៥ ភាគរយ) មានតម្លៃ ៤៣៧ ដុល្លារ/តោន បានថយចុះប្រមាណ ១,២ ភាគរយ ធៀបទៅនឹងខែមុន (៤៤២,១ ដុល្លារ/តោន) ។ ការធ្លាក់ថ្លៃនេះ គឺបណ្តាលមកពីការថយចុះការបញ្ជាទិញរបស់បណ្តាប្រទេស ដែលធ្លាប់បានបញ្ជាទិញកន្លងមក ដូចជាប្រទេសចិន ដែលថ្មីៗនេះបានប្រកាសពីគោលនយោបាយជំរុញការបញ្ជាទិញផលិតផលពីកសិកររបស់ខ្លួន ។

**ថ្លៃកៅស៊ូ÷** នៅខែ តុលា ឆ្នាំ ២០១៤ កៅស៊ូឆៅស្តង់ដារប្រទេសម៉ាឡេស៊ី Standardized Malaysian Rubber (SMR) ប្រភេទ CV នៅទីផ្សារម៉ាឡេស៊ីមានតម្លៃ ១.៩៦៨ ដុល្លារ/តោន គឺបានថយចុះ ៧,៩ ភាគរយ បើប្រៀបធៀបទៅនឹងខែមុន ដែលមានតម្លៃ ២.១៣៤ ដុល្លារ/តោន ។ ប្រការនេះ គឺដោយសារមានការធ្លាក់ចុះតម្រូវការក្នុងឧស្សាហកម្មរបស់ប្រទេសចិន ។

***********

# សូចនាករនាំមុខ (Leading Indicators)


















# អតិផរណា និង ទុនបំរុងបរទេស (Inflation and Foreign Reserves)



Source: NIS



Source: NIS



Source: NIS



Source: NBC



Source: NBC



Source: NIS

# អត្រាប្តូរប្រាក់ (Exchange Rate)

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**Exchange rate R/100Đ and R/B**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)



Source: NBC



Source: NBC



Source: NBC



Source: NBC



Source: NBC



Source: NBC

# ការអនុវត្តថវិកា (Budget)

### ចំណូល និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ




### ចំណូលពន្ធ និង មិនមែនពន្ធឆ្នាំ ២០១៣-២០១៤




### ចំណាយ បៀវត្ស និងមិនមែនបៀវត្សឆ្នាំ ២០១៣-




### ចំណាយ ការពារសន្តិសុខ និងរបាលស៊ីវិលឆ្នាំ ២០១៣-




### ការដកសាច់ប្រាក់របស់ADB និង WB ឆ្នាំ ២០១៣-




### ចំណូលចរន្ត និង វិនិយោគឆ្នាំ ២០១៣-២០១៤



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs Dept.